**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១២.៥៧.ខ.....

# សារលិខិត

**របស់**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
**ក្នុងឱកាសខួប ១០០ឆ្នាំ របស់អង្គការអន្តរជាតិខាងការងារ**
**ខួប ៥០ឆ្នាំ នៃសមាជិកភាពរបស់កម្ពុជានៅអង្គការអន្តរជាតិខាងការងារ និង**
**ខួបអនុស្សាវរីយ៍លើកទី១៣៣ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៩**

***បងប្អូន ក្មួយៗ កម្មករនិយោជិត និយោជក និងជនរួមជាតិទាំងអស់ជាទីស្នេហា!***

តាងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្ដីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានចូលរួមជាមួយបងប្អូន ក្មួយៗ កម្មករនិយោជិត និយោជក និងជនរួមជាតិទាំងអស់ក្នុងឱកាសខួប ១០០ឆ្នាំ (១៩១៩-២០១៩) របស់អង្គការអន្តរជាតិខាងការងារ និងខួប៥០ឆ្នាំ (១៩៦៩-២០១៩) នៃសមាជិកភាពរបស់កម្ពុជានៅអង្គការអន្តរជាតិខាងការងារ ក្រោមប្រធានបទ " **បង្កើនយុត្តិធម៌សង្គម លើកកម្ពស់ការងារសមរម្យ** " និងខួបអនុស្សាវរីយ៍លើកទី១៣៣ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា ក្រោមប្រធានបទ " **កិច្ចគាំពារសង្គមដើម្បីផលិតភាព** "។ នេះជាឱកាសដ៏វិសេសវិសាល ដើម្បីវាយតម្លៃអំពីវឌ្ឍនភាពក្នុងភាពជាដៃគូរបស់ព្រះរាជាណាចក្រកម្ពុជា ជាមួយអង្គការអន្តរជាតិខាងការងារ និងក្នុងឋានៈជាប្រទេសសមាជិករបស់អង្គការអន្តរជាតិខាងការងារ ដែលជាទីភ្នាក់ងារត្រីភាគីឯកទេសផ្នែកពិភពការងាររបស់អង្គការសហប្រជាជាតិ ដែលត្រូវបានបង្កើតនៅឆ្នាំ១៩១៩ ដើម្បីកំណត់បទដ្ឋានការងារ និងរៀបចំគោលនយោបាយនានា ក្នុងគោលបំណងបង្កើនយុត្តិធម៌សង្គម និងលើកកម្ពស់ការងារសមរម្យសម្រាប់ស្ត្រី និងបុរស។

បន្ទាប់ពីទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ ព្រះរាជាណាចក្រកម្ពុជាបានចូលជាសមាជិកអង្គការអន្តរជាតិខាងការងារ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៩។ ក្នុងរយៈពេល៥០ឆ្នាំ កម្ពុជាបានផ្ដល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិចំនួន១៣ ក្នុងនោះមានអនុសញ្ញាស្នូលទាំង៨ និងបានធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមបីប្រទេសនៅក្នុងតំបន់អាស៊ាន ដែលបានផ្ដល់សច្ចាប័នលើអនុសញ្ញាស្នូលខាងការងារទាំង៨។ ខ្លឹមសារនៃអនុសញ្ញាអន្តរជាតិទាំងនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់កម្ពុជា។

តាមរយៈគោលនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់នូវអាទិភាពខ្ពស់ទៅលើសុខសន្តិភាព ស្ថិរភាព ដែលជាគន្លឹះនៃការអភិវឌ្ឍ បានធ្វើឱ្យកម្ពុជាទទួលជោគជ័យយ៉ាងធំធេងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ដែលធ្វើឱ្យមានកំណើនជាមធ្យម ៧% ក្នុងរយៈពេលជាង២ទស្សវត្សរ៍ ហើយបង្កើតការងារធ្វើក្នុងអត្រា ៩៩,៣% នៃកម្លាំងពលកម្មសរុបប្រមាណជា១០លាននាក់ ក្នុងនោះសហគ្រាស គ្រឹះស្ថានសេដ្ឋកិច្ចក្នុងប្រព័ន្ធចំនួនជិត១ម៉ឺន ៣ពាន់ ដែលមានកម្មករនិយោជិតជិត១លាន ៥សែននាក់ សហគ្រាស គ្រឹះស្ថានសេដ្ឋកិច្ចក្រៅប្រព័ន្ធសរុបចំនួនជិត៦សែន ដែលមានកម្មករនិយោជិតជិត ២លាន ៤សែននាក់ វិស័យកសិកម្មប្រមាណជាង៤លាននាក់ ពលករធ្វើការនៅក្រៅប្រទេសចំនួនប្រមាណជា ១លាន ២សែននាក់ និងមន្ត្រីសាធារណៈចំនួនប្រមាណជាង ៥សែននាក់។ បន្ថែមលើនេះ រាជរដ្ឋាភិបាលបានអភិវឌ្ឍសេវាកការងារធ្វើជូនប្រជាពលរដ្ឋ តាមរយៈទីភ្នាក់ងារជាតិមុខរបរ និងការងារ សម្រាប់ការងារក្នុងប្រទេស និងតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ សម្រាប់ការងារក្រៅប្រទេស។

រាជរដ្ឋាភិបាលបានបន្តយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍទំនាក់ទំនងវិជ្ជាជីវៈ ដោយបានបង្កើតឱ្យមានយន្តការត្រីភាគីសម្រាប់សំវាទសង្គមនិងការដោះស្រាយបញ្ហាជាច្រើនទាក់ទងទៅនឹងសិទ្ធិ និងផលប្រយោជន៍របស់កម្មករនិយោជិតនិងនិយោជក មានជាអាទិ៍ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាយន្តការដោះស្រាយវិវាទការងារប្រកបដោយវិជ្ជាជីវៈ និងមានការទទួលស្គាល់ពីគ្រប់មជ្ឈដ្ឋាន។ ចាប់ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០១៨ ក្រុមប្រឹក្សានេះបានដោះស្រាយវិវាទការងារចំនួន ២ ៨០០ករណី ហើយបានជោគជ័យចំនួនជាង៧៣%។ គណៈកម្មការប្រឹក្សាការងារបានចរចាកំណត់បទដ្ឋានពាក់ព័ន្ធជាច្រើន បានបង្កើតក្រុមការងារត្រីភាគីសម្រាប់ចរចាប្រាក់ឈ្នួលអប្បបរមា និងបានដោះស្រាយការកំណត់ប្រាក់ឈ្នួលអប្បបរមាប្រកបដោយសុខដុមរមនា។

រាជរដ្ឋាភិបាលបានបន្តយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សិទ្ធិការងារ និងសេរីភាពអង្គការវិជ្ជាជីវៈ តាមរយៈការពង្រឹងប្រព័ន្ធអធិការកិច្ចការងារ ការអនុវត្តច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសហជីព ស្របតាមអនុសញ្ញាអន្តរជាតិខាងការងារ ដែលកម្ពុជាបានផ្តល់សច្ចាប័ន។ គិតមកដល់ខែធ្នូ ឆ្នាំ២០១៨ ចំនួនសហជីពសរុបដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន ៤ ៨៣៨ ក្នុងនោះ សហជីពមូលដ្ឋានមានចំនួន ៤ ៦២១ សហព័ន្ធសហជីពមានចំនួន ១៨០ សហភាពសហជីពមានចំនួន ២៨ សមាគមនិយោជកមានចំនួន០៩។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាលក៏បានបង្កើតកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគី ក្នុងកិច្ចការពារសិទ្ធិពលករទេសន្តរប្រវេសន៍កម្ពុជាចំនួនជាង១លាន ២សែននាក់ ដែលបានបញ្ជូនប្រាក់បញ្ញើមកក្នុងប្រទេសចំនួនប្រមាណជាង២ពាន់លានដុល្លារអាមេរិកក្នុង១ឆ្នាំ រួមចំណែកក្នុងចំណូលជាតិ។

រាជរដ្ឋាភិបាលបានបន្តយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍអនាម័យ និងសន្តិសុខការងាររបស់កម្មករនិយោជិតមកទល់ពេលនេះ រោងចក្រ សហគ្រាសប្រមាណ ៨៨% មានគិលានដ្ឋានប្រចាំរោងចក្រ កន្លែងហូបបាយបន្ទប់បំបៅកូន និងទារកដ្ឋាន ដែលបានជួយសម្រួលដល់បញ្ហាសុខុមាលភាពរបស់កម្មករនិយោជិត កាត់បន្ថយបញ្ហាដួលសន្លប់ គ្រោះថ្នាក់ការងារ បង្កើនសុវត្ថិភាពក្នុងការដឹកជញ្ជូននិងការធ្វើដំណើររបស់កម្មករនិយោជិត។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវផែនការជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្ពោះទៅការបញ្ចប់ពលកម្មកុមារនៅឆ្នាំ២០២៥។ គិតត្រឹមឆ្នាំ២០១២ ដល់ឆ្នាំ២០១៨ ពលកម្មកុមារត្រូវបានកាត់បន្ថយពីទម្រង់ធ្ងន់ធ្ងរបំផុតប្រមាណពី ៤២ម៉ឺននាក់ មកត្រឹមប្រមាណ ២០ម៉ឺននាក់ និងកំពុងបន្តការងារនេះយ៉ាងសកម្ម។

រាជរដ្ឋាភិបាលបានបន្តយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍរបបសន្តិសុខសង្គម ដើម្បីលើកកម្ពស់សុខុមាលភាពរបស់កម្មករនិយោជិត បង្កើនផលិតភាព និងសមធម៌សង្គម។ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៨ ដែលបានរៀបចំដាក់ឱ្យដំណើរការនូវរបបហានិភ័យការងារ និងថែទាំសុខភាព ដែលមកទល់ពេលនេះមានសហគ្រាស និងគ្រឹះស្ថានជាង១ម៉ឺនជាសមាជិក និងមានកម្មករនិយោជិតនិងមន្ត្រីសាធារណៈ ១លាន ៥សែននាក់កំពុងទទួលបានអត្ថប្រយោជន៍ពីរបបទាំងពីរនេះ ហើយនៅឆ្នាំ២០១៩នេះ រាជរដ្ឋាភិបាលនឹងដាក់ឱ្យដំណើរការរបបសោធនសម្រាប់កម្មករនិយោជិត និងរបបហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ ព្រមទាំងរៀបចំកិច្ចសហប្រតិបត្តិការភ្ជាប់របបសន្តិសុខសង្គម ជាមួយប្រទេសដែលទទួលពលករកម្ពុជា។ រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយឧបត្ថម្ភសាច់ប្រាក់ជូនដល់កម្មការិនីទាំងក្នុងនិងក្រៅប្រព័ន្ធនិងមន្ត្រីសាធារណៈនៅពេលសម្រាលកូន មកទល់ពេលនេះមានកម្មការិនីសរុបចំនួន៦ម៉ឺន ៥៣ាន់នាក់ និងចំនួនកូនជិត ៦ម៉ឺន ៦៣ាន់នាក់ សរុបជាទឹកប្រាក់អស់ជិត ៦លាន ៦សែនដុល្លារ។

រាជរដ្ឋាភិបាលបានបន្តយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ប្រជាពលរដ្ឋ ដើម្បីបង្កើនសមត្ថភាពធនធានមនុស្សផ្នែកជំនាញវិជ្ជាជីវៈ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងការបង្កើតមុខរបរថ្មីៗ។ កម្ពុជាមានគ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈចំនួន ៣២៥ ក្នុងនោះ មានចំនួន១០៦ ជាគ្រឹះស្ថានស្ថិតនៅក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានបណ្តុះបណ្តាលសិក្ខាកាមជាង ៥ម៉ឺន ៣៣ាន់នាក់ក្នុង១ឆ្នាំ ហើយក្នុងនោះ ចំនួនជាង៩០% ទទួលបានការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា។

រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាច្រើន ដើម្បីបង្កើនល្បឿននៃការអភិវឌ្ឍ និងបង្កើតការងារសមរម្យជូនប្រជាពលរដ្ឋ ដូចជា គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣ កម្មវិធីការងារសមរម្យប្រចាំប្រទេសកម្ពុជាលើកទី៥ សម្រាប់ឆ្នាំ២០១៩-២០២៣ ដែលនឹងត្រូវប្រកាសឱ្យប្រើប្រាស់នៅក្នុងឆ្នាំ២០១៩នេះ។

រាជរដ្ឋាភិបាលបាននិងបន្តកិច្ចសហប្រតិបត្តិការ ក្នុងការអនុវត្តនូវគម្រោងអភិវឌ្ឍលក្ខខណ្ឌការងារ សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈប្រកបដោយតម្លាភាព ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ លើកកម្ពស់ផលិតភាពនិងជីវភាព មានជាអាទិ៍គោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្មទៅនឹងលក្ខខណ្ឌការងារ ការបន្តវគ្គមានគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) គម្រោងបទដ្ឋានសង្គមនិងការងារក្នុងវិស័យវាយនភណ្ឌនិងកាត់ដេរក្នុងតំបន់អាស៊ី (GIZ-SLSG) គម្រោងគំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងសកល (Global Deal Initiative) និងគម្រោងផ្សេងៗជាច្រើនទៀត។

***បងប្អូន ក្មួយៗ កម្មករនិយោជិត និយោជក និងជនរួមជាតិទាំងអស់ជាទីស្នេហា!***

កន្លងទៅនេះ ដើម្បីជំរុញការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍវិស័យឧស្សាហកម្ម មុខរបរនិងការងារ និងគាំពារសង្គម ខ្ញុំផ្ទាល់បានចុះជួបជាមួយនឹងកម្មករនិយោជិត គិតចាប់ពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៧ មកទល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ គឺមានរយៈពេល១៩ខែ និង៨ថ្ងៃ បានចំនួន៦៦លើក សរុបកម្មករនិយោជិតចំនួនជិត ៩ សែន ៥ ម៉ឺននាក់ ដែលតាមរយៈនេះ បានរកឃើញបញ្ហានិងដាក់ចេញនូវគោលការណ៍និងវិធានការជាច្រើន ជាពិសេសអនុសាសន៍១០ចំណុច ដើម្បីលើកកម្ពស់ជីវភាព សុខុមាលភាពកម្មករនិយោជិត

និងទំនាក់ទំនងវិជ្ជាជីវៈ ហើយខ្ញុំនឹងបន្តសកម្មភាពនេះជារៀងរហូតនៅក្នុងតំណែងរបស់ខ្ញុំជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

រាជរដ្ឋាភិបាលនឹងបន្តផ្តល់នូវកិច្ចសហការជាមួយនឹងអង្គការអន្តរជាតិខាងការងារ និងដៃគូអភិវឌ្ឍន៍នានាឱ្យបានជិតស្និទ្ធថែមទៀត ដើម្បីរួមគ្នាសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ និងដើម្បីសម្រេចមហិច្ឆតាប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់បងប្អូនជនរួមជាតិដែលកំពុងធ្វើការទាំងក្នុង និងក្រៅប្រទេស ក៏ដូចជាអស់លោក លោកស្រី ជានិយោជក និងនិយោជិតបរទេស ជាមន្ត្រីអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលកំពុងស្នាក់នៅ និងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា នូវពុទ្ធពរនិងពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ ចន្ទ ៥ រោច ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ មីនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**